# សេចក្តីណែនាំ

# ការសរសេរនិក្ខេបបទបណ្ឌិត

## សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប

GUIDELINES FOR THE DOCTORAL DISSERTATION

ASIA EURO UNIVERSITY

## សាលាក្រោយឧត្តម

POST-GRADUATE SCHOOL

ព.ស.២៥៦៥ គ.ស.២០២១

# មាតិកា

មាតិកា ........................................................................................................ i
បុព្វកថា........................................................................................................ 1
សេចក្តីផ្តើម........................................................................................................ 2

## ជំពូកទី១

## ការជ្រើសរើសប្រធានបទ និងសាស្ត្រាចារ្យណែនាំ

១.១. ការជ្រើសរើសប្រធានបទស្រាវជ្រាវ........................................ 4
១.២. ក្រុមសាស្ត្រាចារ្យណែនាំ........................................................ 5
១.២.១. សាស្ត្រាចារ្យណែនាំគោល ................................................ 5
១.២.២. សាស្ត្រាចារ្យណែនាំរង.................................................... 6
១.២.៣. ភារកិច្ចនិងការទទួលខុសត្រូវរបស់សាស្ត្រាចារ្យណែនាំ ............ 6

## ជំពូកទី២

## ការសរសេរគម្រោងស្រាវជ្រាវបឋម

២.១. សេចក្តីផ្តើម........................................................................ 8
២.២. ចំណងជើងប្រធានបទបណ្ដោះអាសន្ន ...................................... 8
២.៣. ចំណោទបញ្ហានៃការស្រាវជ្រាវ................................................ 9
២.៤. គោលបំណងនៃការស្រាវជ្រាវ ............................................... 10
២.៥. សម្មតិកម្ម.......................................................................... 11
២.៦. វិសាលភាព និងដែនកំណត់ ................................................... 11
២.៧. វិធីសាស្ត្រស្រាវជ្រាវ ............................................................ 12
២.៨. ប្លង់និក្ខេបបទបណ្ដោះអាសន្ន.................................................. 12
២.៩. ប្រតិទិនស្រាវជ្រាវ............................................................... 13
២.១០. ការតម្រង់ទិសឯកសារពិគ្រោះ.............................................. 13
២.១១. ការការពារគម្រោងស្រាវជ្រាវបឋម......................................... 13
២.១២. ការប្រកាសលទ្ធផល .......................................................... 14

## ជំពូកទី៣
## ការសរសេរនិក្ខេបបទ


៣.១. ការសរសេរជំពូកទី១ ........................................................ 16
៣.២. ការសរសេរជំពូកទី២ ........................................................ 19
៣.៣. ការសរសេរជំពូកទី៣ ........................................................ 20
៣.៤. ការសរសេរជំពូកទី៤ ........................................................ 23
៣.៥. ការសរសេរជំពូកទី៥ ........................................................ 25
៣.៦. ការសរសេរជំពូកទី៦ ........................................................ 26


## ជំពូកទី៤
## រចនាសម្ព័ន្ធទូទៅនៃនិក្ខេបបទបណ្ឌិត


៤.១. រចនាសម្ព័ន្ធទូទៅ ........................................................ 28
៤.២. ខ្នាតគំរូនិក្ខេបបទ ........................................................ 29
៤.២.១. ក្របមុខ ........................................................ 29
៤.២.២. ទំព័រទំនេរ ក្រដាស ........................................................ 30
៤.២.៣. ទំព័រចំណងជើង ........................................................ 30
៤.២.៤. ខ្នងក្របនិក្ខេបបទ ........................................................ 30
៤.៣. ទំហំក្រដាស ប្រភេទអក្សរ និងទំហំអក្សរ ........................................ 31
៤.៣.១. ការកំណត់ទំហំក្រដាស (Page Setup) ........................................ 31
៤.៣.២. អក្សរខ្មែរ (យូនីកូដ) ........................................................ 31
៤.៣.៣. អក្សរឡាតាំង ........................................................ 31
៤.៣.៤. លេខទំព័រ ........................................................ 32
៤.៤. ការសរសេរកំណត់សម្គាល់ជើងទំព័រ និងគន្ថនិទ្ទេស ........................ 32
៤.៥. ផ្នែកឧបសម្ព័ន្ធ ........................................................ 39
៤.៦. ការកំណត់ទំព័រនិក្ខេបបទ ........................................................ 40


## ជំពូកទី៥

## នីតិវិធី យន្តការការពារនិក្ខេបបទ
## និងការប្រគល់សញ្ញាបត្រថ្នាក់បណ្ឌិត


៥.១. ការការពារគម្រោងស្រាវជ្រាវពិស្តារ ........................................ 41
៥.១.១. លក្ខខណ្ឌ និងការបំពេញសំណុំឯកសារ ........................ 42
៥.១.២. យន្តការនៃដំណើរការការពារ ........................................ 43
៥.១.៣. ការប្រកាសលទ្ធផលការពារ ........................................ 43
៥.២. ការការពារនិក្ខេបបទសាកល្បង ........................................ 43
៥.២.១. លក្ខខណ្ឌ និងការបំពេញសំណុំឯកសារ ........................ 43
៥.២.២. យន្តការនៃដំណើរការការពារ ........................................ 44
៥.២.៣. ការប្រកាសលទ្ធផលការពារ ........................................ 45
៥.៣. ការការពារនិក្ខេបបទបញ្ចប់ ................................................ 45
៥.៣.១. លក្ខខណ្ឌ និងការបំពេញសំណុំឯកសារ ........................ 45
៥.៣.២. យន្តការនៃដំណើរការការពារ ........................................ 46
៥.៣.៣. ការប្រកាសលទ្ធផលការពារ ........................................ 46
៥.៤. លក្ខខណ្ឌសម្រាប់អនុញ្ញាតឱ្យការពារនិក្ខេបបទបញ្ចប់ .............. 47
៥.៥. ការការពារនិក្ខេបបទឡើងវិញ ............................................ 48
៥.៦. របៀបវារៈនៃដំណើរការការពារ ............................................ 48
៥.៧. លិខិតូបករណ៍ .................................................................. 49
៥.៨. ការប្រគល់សញ្ញាបត្រ ......................................................... 49
៥.៨.១. វិញ្ញាបនបត្របណ្ដោះអាសន្ន ........................................ 49
៥.៨.២. ការតម្កល់និក្ខេបបទ និងសញ្ញាបត្របណ្ឌិត .................... 49

# ជំពូកទី៤
# រចនាសម្ព័ន្ធទូទៅនៃនិក្ខេបបទបណ្ឌិត

បេក្ខជនបណ្ឌិត តម្រូវឱ្យយកគំរូតាមរចនាសម្ព័ន្ធនៃនិក្ខេបបទបណ្ឌិត ដូចខាងក្រោមនេះ៖

## ៤.១. រចនាសម្ព័ន្ធទូទៅ

១- ក្របមុខ

២- ទំព័រទំនេរ

៣- ទំព័រចំណងជើង(ក្របទី២)

៤- គណៈកម្មការការពារនិក្ខេបបទ

៥- សេចក្តីបញ្ជាក់របស់សាស្ត្រាចារ្យណែនាំ

៦- មាតិកា

៧- ឧទ្ទិសកថា

៨- សេចក្តីថ្លែងអំណរគុណ

៩- អំណះអំណាង

១០- មូលន័យសង្ខេប ជាភាសាជាតិ

១១- មូលន័យសង្ខេប ជាភាសាអង់គ្លេស (Abstract)

១២- អក្សរសង្ខេប

១៣- បញ្ជីតារាង

១៤- បញ្ជីរូប

១៥- ខ្លឹមសារនិក្ខេបបទ

ជំពូកទី១ សេចក្តីផ្តើម

ជំពូកទី២ ការសំយោគឯកសារពាក់ព័ន្ធ

ជំពូកទី៣ វិធីសាស្ត្រស្រាវជ្រាវ

ជំពូកទី៤ លទ្ធផលនៃការស្រាវជ្រាវ

ជំពូកទី៥ ការពិភាក្សាលើលទ្ធផលនៃការស្រាវជ្រាវ

ជំពូកទី៦ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១៦- គន្ថនិទ្ទេស

១៧- ឧបសម្ព័ន្ធ

## ៤.២. ខ្នាតគំរូនិក្ខេបបទ

### ៤.២.១. ក្របមុខ

បេក្ខជនបណ្ឌិតគួរប្រើពាក្យពេចន៍ ឃ្លាប្រយោគងាយស្រួលអាន និងយល់។ ចំណុចសំខាន់ៗនៃក្របមុខរួមមាន៖

-ក្រដាស៖ ក្រដាសរឹងពណ៌ខៀវចាស់ តំណាងសារធាតុបញ្ញាជន (លេខកូដពណ៌: C:75, M:68, Y:66, K:90)

-ពណ៌អក្សរ៖ ចារឹកដោយអក្សរពុម្ពពណ៌ទឹកមាសភ្លឺ។

-ខ្លឹមសារលើក្របមុខរួមមាន៖

ក-ក្រសួងអប់រំ យុវជន និងកីឡា (Font: Khmer OS Muol Light, Size: 16)

ខ-ឈ្មោះគ្រឹះស្ថាន៖ មាន Logo សាកលវិទ្យាល័យនៅផ្នែកខាងឆ្វេង និងឈ្មោះសាកលវិទ្យាល័យ (Font: Khmer OS Muol Light, Size: 14) និងសាលាក្រោយឧត្តម (Font: Khmer OS Muol Light, Size: 9)។

គ-ឈ្មោះបេក្ខជនបណ្ឌិត៖ (Font: Khmer OS Muol Light, Size: 14)

ឃ-ប្រធានបទ៖ ជាចំណងជើងគោលជាភាសាជាតិ និងមានបកប្រែជាភាសាអង់គ្លេស។ ចំណងជើងគោលប្រើអក្សរពុម្ពជាភាសាជាតិ Font: Khmer OS Moul Light, Size: 22, និងភាសាអង់គ្លេស Font: Khmer OS Moul Light, Size: 20

ង-និក្ខេបបទបណ្ឌិតស្រាវជ្រាវ និងឯកទេស Font: Khmer OS Muol Light, Size: 14

ច-ភ្នំពេញ និងឆ្នាំ (ឱ. ២៥៦៥/២០២១) សរសេរ Font: Khmer OS Muol Light, Size: 14

### ៤.២.២. ទំព័រទំនេរ ក្រដាសៈ ព៌ណស៊ីហ្គិច

### ៤.២.៣. ទំព័រចំណងជើង

ក្រដាសពណ៌សអក្សរពណ៌ខ្មៅ រួមមានចំណុចសំខាន់ៗ ដូចខាងក្រោមៈ

១- Logo សាកលវិទ្យាល័យ

២- ឈ្មោះសាកលវិទ្យាល័យ Font: Khmer OS Muol Light, Size: 14

៣- សាលាក្រោយឧត្តម Font: Khmer OS Muol Light, Size: 9

៤- ឈ្មោះនិស្សិត Font: Khmer OS Muol Light, Size: 14

៥- ប្រធានបទ Font: Khmer OS Muol Light, Size: 22

៦- និក្ខេបបទបណ្ឌិតស្រាវជ្រាវ ឬបណ្ឌិតវិជ្ជាជីវៈ និងឯកទេស Font: Khmer OS Muol Light, Size: 14

៧- ឈ្មោះសាស្ត្រាចារ្យណែនាំ Font: Khmer OS Muol Light, Size: 14

៨- ជំនាន់ទី... Font: Khmer OS Muol Light, Size: 14

៩- ការពារ.... ឆ្នាំ.... Font: Khmer OS Muol Light, Size: 14

### ៤.២.៤. ខ្លងក្របនិក្ខេបបទ

១)-Logo សាកលវិទ្យាល័យ

២)-ឈ្មោះ សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ជាអក្សរកាត់គឺ សអអ

៣)-ប្រធានបទ

៤)-ឈ្មោះបេក្ខជនបណ្ឌិត

៥)-ឆ្នាំ...

## ៤.៣. ទំហំក្រដាស ប្រភេទអក្សរ និងទំហំអក្សរ

ទំហំក្រដាស ហ្វុងអក្សរ និងទំហំអក្សរ មានការកំណត់ដូចខាងក្រោម៖

### ៤.៣.១. ការកំណត់ទំហំក្រដាស (Page Setup)

ទំហំក្រដាស៖ A4

| | | | | |
|---|---|---|---|---|
| Margin: | (Normal) | -Top | : | 2.54 cm |
| | | - Bottom | : | 2.54 cm |
| | | - Left | : | 2.54 cm |
| | | - Right | : | 2.54 cm |
| Paragraph: (Spacing) | | -Before | : | 0 pt |
| | | - After | : | 0 pt |
| | | - Line spacing: | | 1.5 lines |

### ៤.៣.២. អក្សរខ្មែរ (យូនីកូដ)

-ចំណងជើងធំពូក ៖ Khmer OS Moul Light–Size 14

-ចំណងជើងរង ៖ Khmer OS Moul Light–Size 12

-ចំណងជើងតូច ៖ Khmer OS Moul Light – Size 11

-ចំណងជើងតូចបន្ទាប់ ៖ Khmer OS Moul Light – Size 10

-ខ្លឹមសារអត្ថបទ ៖ Khmer OS Siemreap – Size 12

-ឯកសារយោង (Footnotes) ៖ Khmer OS Siemreap–Size 9

### ៤.៣.៣. អក្សរឡាតាំង

-ចំណងជើងធំពូក ៖ Khmer OS Siemreap –Size 12

-ចំណងជើងរង ៖ Khmer OS Siemreap – Size 12

-ចំណងជើងតូច ៖ Khmer OS Siemreap – Size 11

-ខ្លឹមសារអត្ថបទ ៖ Khmer OS Siemreap – Size 12

-ឯកសារយោង (Footnotes) ៖ Khmer OS Siemreap – Size 09

### ៤.៣.៤. លេខទំព័រ

ចាប់ពីសេចក្ដីបញ្ជាក់របស់សាស្ត្រាចារ្យណែនាំ អំណរអំណាង ឧទ្ទិសកថា សេចក្ដីថ្លែងអំណរគុណ មូលន័យសង្ខេប អក្សរសង្ខេប បញ្ជីតារាង បញ្ជីរូបមាតិកា ត្រូវប្រើលេខរ៉ូម៉ាំងតូច (i, ii, iii,...)។ នៅក្នុងតួសេចក្ដី នៃនិក្ខេបបទប្រើលេខធម្មតា (១, ២, ៣,...៣០០)។ ការប្រើលេខបែងចែងផ្នែក៖ នៅពេលបែងចែងផ្នែក ប្រើលេខធម្មតា (១.១., ១.២., ១.៣., ២.១., ២.២., ២.៣., ៣.១., ៣.២., ៣.៣.,...)។ ប៉ុន្តែសម្រាប់បែងចែកផ្នែករងប្រើ (១.១.១., ១.១.២., ១.១.៣.,...)។ បើមានផ្នែកបន្ថែមទៀត ត្រូវប្រើ (ក., ខ., គ., ឃ.,...)។ ដោយឡែកចំពោះគន្ថនិទ្ទេស, ឧបសម្ព័ន្ធ, និងសន្ទានុក្រមវិញ ត្រូវប្រើលេខអារ៉ាប់ (1, 2, 3, 4, 5, 6, 7, 8, 9,...)។

## ៤.៤. ការសរសេរកំណត់សម្គាល់ជើងទំព័រ និងគន្ថនិទ្ទេស

ការសរសេរកំណត់សម្គាល់ជើងទំព័រ និងគន្ថនិទ្ទេស សាកលវិទ្យាល័យបានកំណត់គំរូក្នុងការសរសេរឯកសារនេះ ដោយយកតាមប្រព័ន្ធដែលគេនិយមជាងគេបំផុតនៅលើសកលលោក (គំរូ APA) ដោយបានកំណត់គំរូសម្រាប់ប្រើប្រាស់ប្រចាំសាកលវិទ្យាល័យ ឬអាចនិយាយបានថា *"របៀបសរសេរតាមបែបសាកលវិទ្យាល័យ អាស៊ី អឺរ៉ុប"*។

កំណត់សម្គាល់ជើងទំព័រភាគច្រើន ជាកំណត់ត្រាខ្លឹមសារ ដែលដាក់ឬប្រាប់អំពីឯកសារដែលចាំបាច់ក្នុងការបំពេញបន្ថែម ឬបង្កើនខ្លឹមសារឱ្យកាន់តែខ្លាំងដល់ព័ត៌មានដែលកំពុងលើកក្នុងអត្ថបទ។ វាត្រូវបានគេបង់លេខបន្តបន្ទាប់គ្នានៅខាងលើនៃចុងព័ត៌មានណាមួយ ដែលគេចង់បញ្ជាក់នៅក្នុងអត្ថបទ រួចហើយទើបគេបកស្រាយបញ្ជាក់និមិត្តសញ្ញានៃលេខនោះ នៅជើងទំព័រខាងក្រោមដោយទំហំអក្សរតូចៗ។

ចំណែកឯ ការសរសេរគន្ថនិទ្ទេស (Bibliography) ជាបញ្ជីនៃឯកសារពិគ្រោះ និងយោង ដែលដាក់នៅខាងចុងស្នាដៃ ដែលត្រូវបានតម្រៀបតាមលំដាប់អក្ខរក្រមតាមប្រភេទឯកសារ និងភាសានីមួយៗ ដើម្បីប្រាប់ពី

ប្រភពឯកសារយោង និងឯកសារពិគ្រោះទាំងឡាយដែលបានយកមកប្រើប្រាស់ក្នុងអត្ថបទនេះ។

ការសរសេរកំណត់សម្គាល់ជើងទំព័រ និងគន្ថនិទ្ទេស មានបីផ្នែកដែលត្រូវបង្ហាញជាចាំបាច់ ដូចខាងក្រោម៖

| | |
|---|---|
| ផ្នែកទី១ ៖ | នាមត្រកូល និងនាមខ្លួនអ្នកនិពន្ធ |
| ផ្នែកទី២ ៖ | ចំណងជើង |
| ផ្នែកទី៣ ៖ | -កន្លែងបោះពុម្ពផ្សាយ<br>-ឈ្មោះអ្នកបោះពុម្ពផ្សាយ<br>-កាលបរិច្ឆេទបោះពុម្ពផ្សាយ<br>-លេខទំព័រ |

| | | |
|---|---|---|
| ប៊ុណ្ណ ចន្ទ ម៉ុល៖ | *ចរិតខ្មែរ* | ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ១៩៧២ ទំព័រ...។ |
| (ផ្នែកទី១) | (ផ្នែកទី២) | (ផ្នែកទី៣) |

| | | |
|---|---|---|
| S. Ratnagar, | *Trading Encounters: From the Euphrates to the Indus in the Bronze Age,* | New Delhi, Oxford University Press, 2004, p. 23 |
| (ផ្នែកទី១) | (ផ្នែកទី២) | (ផ្នែកទី៣) |

ការបង្ហាញកំណត់សម្គាល់ជើងទំព័រ និងគន្ថនិទ្ទេស មានករណីណាមួយក្នុងចំណោមករណីឧទាហរណ៍ដូចខាងក្រោម៖

| **Material Type** | **Footnote Example** | **Reference or Bibliography List Example** |
|---|---|---|
| **Books** | | |
| Book: Single Author | [1] ប៊ុន ចន្ទម៉ុល៖ *ចរិតខ្មែរ* ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ១៩៧២ ទំព័រ ១៨។ | ប៊ុន ចន្ទម៉ុល៖ *ចរិតខ្មែរ* ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ១៩៧២។ |
| | [1] S. Ratnagar, *Trading Encounters: From the Euphrates to the Indus in the Bronze Age,* New Delhi, Oxford University Press, 2004, p. 23. | Ratnagar, S., *Trading Encounters: From the Euphrates to the Indus in the Bronze Age,* New Delhi, Oxford University Press, 2004. |

| | | |
|---|---|---|
| Book: 2 or 3 Authors | [1] ថាច់ វ៉ាន់ផាត និង កែវ សុគុន៖ *អាទិទេពក្រុងអង្គរ* ភ្នំពេញ រោងពុម្ពរាស្ត្រសច្ចៈ ១៩៧៣ ទំព័រ ១៨។ | ថាច់ វ៉ាន់ផាត និង កែវ សុគុន៖ *អាទិទេពក្រុងអង្គរ* ភ្នំពេញ រោងពុម្ពរាស្ត្រសច្ចៈ ១៩៧៣។ |
| | [1] A. Blackledge and A. Creese, *Multilingualism: a Critical Perspective*, London, Continuum, 2010, p. 10. | Blackledge, A. and A. Creese, *Multilingualism: a Critical Perspective*, London,Continuum, 2010. |
| Book: 4 or more Authors | [1] ឥន្ទ ឱមសាម៉េង និងសហការី៖ *សេដ្ឋកិច្ច និងមនុស្សនៃប្រទេសកម្ពុជា* ភ្នំពេញ រោងពុម្ពជោគជ័យ ២០១៣-២០១៤ ទំព័រ ៣៥។ | ឥន្ទ ឱមសាម៉េង និងសហការី៖ *សេដ្ឋកិច្ច និងមនុស្សនៃប្រទេសកម្ពុជា* ភ្នំពេញ រោងពុម្ពជោគជ័យ ២០១៣-២០១៤ ។ |
| | [1] A. Kring, et al., *Abnormal Psychology*, 11th edn., Hoboken, NJ, John Wiley & Sons, 2010, p. 40. | Kring, A. et al., *Abnormal Psychology*, 11th edn., Hoboken, NJ, John Wiley & Sons, 2010. |
| Book: No Author | [1] *ក្បួនយុទ្ធសាស្ត្រនាគមាស* ភ្នំពេញ គ្រឹះស្ថានបោះពុម្ពផ្សាយ IDEA BOOK ២០១១ ទំព័រ ៣៥។ | *ក្បួនយុទ្ធសាស្ត្រនាគមាស* ភ្នំពេញ គ្រឹះស្ថានបោះពុម្ពផ្សាយ IDEA BOOK ២០១១។ |
| | [1] *The Cambridge Companion to Postmodernism*, Cambridge, U.K.,Cambridge University Press, 2004, p. 70. | *The Cambridge Companion to Postmodernism*, Cambridge, U.K., Cambridge University Press, 2004. |
| Book: Editor | [1] J.M. Foley (ed.), *A Companion To Ancient Epic*, Oxford, Wiley-Blackwell, 2009, pp. 25-30. | Foley, J.M. (ed.), *A Companion To Ancient Epic*, Oxford, Wiley-Blackwell, 2009. |
| Book: Translator & Author | [1] ប្រេន ត្រាស៊ី និង ពិទ័រ ជី៖ *សិល្បៈនៃការដឹកនាំឆ្ពោះទៅរកឧត្តមភាព* ប្រែសម្រួលដោយ ប្រាជ្ញ វិជ័យ ភ្នំពេញ គ្រឹះស្ថានបោះពុម្ពផ្សាយ ដាំដើមជីវិត ២០១៤ ទំព័រ ៣៥។ | ប្រេន ត្រាស៊ី និង ពិទ័រ ជី៖ *សិល្បៈនៃការដឹកនាំឆ្ពោះទៅរកឧត្តមភាព* ប្រែសម្រួលដោយ ប្រាជ្ញ វិជ័យ ភ្នំពេញ គ្រឹះស្ថានបោះពុម្ពផ្សាយ ដាំដើមជីវិត ២០១៤។ |
| | [1] Y. Aralawa, *Zen Painting*, trans. J. Bester, Tokyo, Kodansha International, 1970, p. 75. | Arakawa, Y., *Zen Painting*, trans. J.Bester, Tokyo, Kodansha International, 1970. |
| Book: Organisation as Author | [1] រាជបណ្ឌិត្យសភាកម្ពុជា៖ *សន្និសីទស្តីពី ការបណ្តុះបណ្តាលធនធាន* | រាជបណ្ឌិត្យសភាកម្ពុជា៖ *សន្និសីទស្តីពី ការបណ្តុះបណ្តាលធនធាន* |

| | | |
|---|---|---|
| | *មនុស្សនៅកម្ពុជា៖ តុល្យការ និងចក្ខុវិស័យ*ភ្នំពេញ រាជបណ្ឌិត្យសភាកម្ពុជា ១៩៩៩ ទំព័រ ១៨។ | *មនុស្សនៅកម្ពុជា៖ តុល្យការ និងចក្ខុវិស័យ* ភ្នំពេញ រាជបណ្ឌិត្យសភាកម្ពុជា ១៩៩៩។ |
| | [1] Australian Bureau of Statistics, Queensland Office, *The Economic Status of Migrants in Australia*, Canberra, Australian Govt. Pub. Service, 1990, p. 320. | Australian Bureau of Statistics, Queensland Office, *The Economic Status of Migrants in Australia*, Canberra, Australian Govt. Pub. Service, 1990. |
| Book: Chapter or Article in Edited Book | [1] J. Baker, 'The Place of Science and Technology in the Wise Management of the Great Barrier Reef', in E. Wolanski (ed.), *Oceanographic Processes of Coral Reefs: Physical and Biological Links in the Great Barrier Reef*, Boca Raton, CRC Press, 2001, pp. 14-20. | Baker, J., 'The Place of Science and Technology in the Wise Management of the Great Barrier Reef', in Wolanski, E. (ed.), *Oceanographic Processes of Coral Reefs: Physical and Biological Links in the Great Barrier Reef*, Boca Raton, CRC Press, 2001, pp. 14-20. |
| Book, edition other than first. | [1] ឥន ឃឿន៖ *នីតិមុខងារសាធារណៈ*: បោះពុម្ពលើកទី២ ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ២០១៦ ទំព័រ ៣៥។ | ឥន ឃឿន៖ *នីតិមុខងារសាធារណៈ*: បោះពុម្ពលើកទី២ ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ២០១៦។ |
| | [1] M.J. Sargent, P. Nilan, and G. Winter, *The New Sociology for Australians*,4th edn., Melbourne, Longman Australia, 1997, p. 140. | Sargent, M.J., P. Nilan and G. Winter, *The New Sociology for Australians*, 4th edn., Melbourne, Longman Australia, 1997. |
| E-book | [1] V. Koller, *Metaphor and Gender in Business Media Discourse: A Critical Cognitive Study*, New York, Palgrave Macmillan, 2004, pp. 75-80, Availablefrom: E-Book Library, (accessed 23 September 2010). | Koller, V., *Metaphor and Gender in Business Media Discourse: A Critical Cognitive Study*, New York, Palgrave Macmillan, 2004, Available from: E-Book Library, (accessed 23 September 2010). |
| E-book: Chapter or Article in an Edited E-book | [1] D. Andrew, 'Time Zones and Jetlag: the Flows and Phases of World Cinema', in K. Newman (ed.), *World Cinemas, Transnational Perspectives*, New York, Routledge, 2009, pp. 59-90, Available from: E-Book Library, (accessed 6 May 2015). | Andrew, D., 'Time Zones and Jetlag: the Flows and Phases of World Cinema', in K. Newman (ed.), *World Cinemas, Transnational Perspectives*, New York, Routledge, 2009, pp. 59-90, Available from: E-Book Library, (accessed 6 May 2015). |
| **Journal Articles** | | |

| | | |
|---|---|---|
| Journal Article: single author (print) | [1] គី សេរីវឌ្ឍន៍៖ "គំរិយាបថជំនួយរបស់ចិន ជប៉ុន និងកូរ៉េ មកកម្ពុជា" *ទស្សនាវដ្ដីស្រាវជ្រាវរបស់សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប* លេខទី៣ ឆ្នាំ ២០១៤ ទំព័រ ៤២។ | គី សេរីវឌ្ឍន៍៖ "គំរិយាបថជំនួយរបស់ចិន ជប៉ុន និងកូរ៉េ មកកម្ពុជា" *ទស្សនាវដ្ដីស្រាវជ្រាវរបស់សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប* លេខទី៣ ឆ្នាំ ២០១៤ ទំព័រ ៤២។ |
| | [1] S. Mintz, 'Food Enigmas, Colonial and Postcolonial', *Gastronomica*, vol. 10, no.1, 2010, p. 149. | Mintz, S., 'Food Enigmas, Colonial and Postcolonial', *Gastronomica*, vol. 10, no. 1, 2010, p. 149. |
| Journal Article: 2 or 3 authors (print) | [1] សោម សុមុនី និង ឆេង វណ្ណារិទ្ធ៖ "ទស្សនវិស័យសម្រាប់ទំនាក់ទំនងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឆ្លងដែនវៀតណាម ឡាវ និងកម្ពុជា" *ទស្សនាវដ្ដីស្រាវជ្រាវរបស់សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប* លេខទី៥ ឆ្នាំ ២០១៦ ទំព័រ ៤២។ | សោម សុមុនី និង ឆេង វណ្ណារិទ្ធ៖ "ទស្សនវិស័យសម្រាប់ទំនាក់ទំនងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឆ្លងដែនវៀតណាម ឡាវ និងកម្ពុជា" *ទស្សនាវដ្ដីស្រាវជ្រាវរបស់សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប* លេខទី៥ ឆ្នាំ ២០១៦ ទំព័រ ៤២។ |
| | [1] P. Addo and N. Besnier, 'When Gifts Become Commodities: Pawnshops, Valuables, and Shame in Tonga and the Tongan Diaspora', *Journal of the Royal Anthropological Institute*, vol. 14, no. 1, 2008, p. 39. | Addo, P. and N. Besnier, 'When Gifts Become Commodities: Pawnshops, Valuables, and Shame in Tonga and the Tongan Diaspora', *Journal of the Royal Anthropological Institute*, vol. 14, no. 1, 2008, p. 39. |
| Journal Article: 4 or more authors (print) | [1] M. Spencer et al., 'Analyzing the Order of Items in Manuscripts of "the Canterbury Tales", *Computers and the Humanities*, vol. 37, no. 1, 2003, pp. 97-109. | Spencer, M. et al., 'Analyzing the Order of Items in Manuscripts of "the Canterbury Tales", *Computers and the Humanities*, vol. 37, no. 1, 2003, pp. 97-109. |
| Journal Article: Electronic Database | [1] K. Toffoletti, 'How is Gender-based Violence Covered in the Sporting News? An Account of the Australian Football League Sex Scandal', *Women's Studies International Forum*, vol. 30, no. 5, 2007, p. 427. Available from ProQuest, (accessed 23 February 2010). | Toffoletti, K. 'How is Gender-based Violence Covered in the Sporting News? An Account of the Australian Football League Sex Scandal', *Women's Studies International Forum*, vol. 30, no. 5, 2007, p. 427. Available from ProQuest, (accessed 23 February 2010). |
| Journal Article: Website | [1] K.R. Moore, 'Was Pythagoras Ever Really in Sparta?', *Rosetta*, no. 6 Spring, 2009, | Moore, K.R., 'Was Pythagoras Ever Really in Sparta?', *Rosetta*, no. 6 Spring, 2009, |

| | | |
|---|---|---|
| | http://www.rosetta.bham.ac.uk, (accessed 10 September 2010). | http://www.rosetta.bham.ac.uk, (accessed 10 September 2010). |
| **Newspapers** | | |
| Newspaper article: print | [1] ម៉ែ គុណមករា៖ "ឥណ្ឌាកំពុងតម្រង់ទៅរកសមាហរណកម្មជាមួយ CLMV" *ខ្មែរថាមស៍* ថ្ងៃទី១៥ ខែមករា ឆ្នាំ ២០១៦ ទំព័រ ៣។ | ម៉ែ គុណមករា៖ "ឥណ្ឌាកំពុងតម្រង់ទៅរកសមាហរណកម្មជាមួយ CLMV" *ខ្មែរថាមស៍* ថ្ងៃទី១៥ ខែមករា ឆ្នាំ ២០១៦ ទំព័រ ៣។ |
| | [1] R. Boyd, 'The City of Sordid Splendour', *Australian*, 26 August 1964, p. 10. | Boyd, R., 'The City of Sordid Splendour', *Australian*, 26 August 1964, p. 10. |
| Newspaper article: Electronic Database | [1] K. Brooks, 'No Surprise in Big Bro Demise,' *Courier-Mail*, 16 July 2008, Available from Factiva, (accessed 3 March 2008). | Brooks, K., 'No Surprise in Big Bro Demise,' *Courier-Mail*, 16 July 2008, Available from Factiva, (accessed 3 March 2008). |
| Newspaper article: Website | [1] ម៉ែ គុណមករា៖ "កម្ពុជាមិនរំពឹងថាទទួលបានដំណក់ប្រេងដំបូងនៅឆ្នាំ២០១៨" *ខ្មែរថាមស៍* ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ http://www.khmertimeskh.com/news/23036/ (បានចូលមើល ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦។ | [1] ម៉ែ គុណមករា៖ "កម្ពុជាមិនរំពឹងថាទទួលបានដំណក់ប្រេងដំបូងនៅឆ្នាំ២០១៨" *ខ្មែរថាមស៍* ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ http://www.khmertimeskh.com/news/23036/ (បានចូលមើល ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦។ |
| | [1] S. Bredow, 'Powder to the People', *Sydney Morning Herald*, 7 June 2008, http://www.smh.com.au/news/ski/ powder-to-the-people/ 2008/06/04/1212258872379.html, (accessed 3 March 2008). | Bredow, S., 'Powder to the People', *Sydney Morning Herald*, 7 June 2008, http://www.smh.com.au/news/ski/powder-to-the-people/ 2008/06/04/1212258872379.html, (accessed 3 March 2008). |
| **Primary Sources** | | |
| Historical Sources | [1] 'George Dewell, Theft, Simple Larceny', *Proceedings of the Old Bailey Online*, 16th February 1832, Ref No: t18320216-60, http://www.oldbaileyonline.org/ index.jsp, (accessed 20 February 2010). | 'George Dewell, Theft, Simple Larceny', *Proceedings of the Old Bailey Online*, 16th February 1832, Ref No: t18320216-60, http://www.oldbaileyonline.org/ index.jsp, (accessed 20 February 2010). |

| | | |
|---|---|---|
| | [1] Lord Cathcart, Diary: Transcript, 1709-28. 16 vols. [A25-A40] National Library of Scotland. | Cathcart, Lord C., Dairy: Transcript, 1709-28. 16 vols. [A25-A40] National Library of Scotland. |
| **Thesis/Dissertation** | | |
| Thesis | [1] ទ្រី ចាន់ធុច៖ "ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា" និក្ខេបបទបណ្ឌិតស្រាវជ្រាវ សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ឆ្នាំ២០១៤ ទំព័រ ២៣។ | ទ្រី ចាន់ធុច៖ "ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា" និក្ខេបបទបណ្ឌិតស្រាវជ្រាវ សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប ឆ្នាំ២០១៤។ |
| | [1] C. Maslem, 'Melancholic Identification and Nostalgic Fantasy in the Novels of Jean Rhys', PhD Thesis, University of Western Australia, 2005, p. 55. | Malsem, C., 'Melancholic Identification and Nostalgic Fantasy in the Novels of Jean Rhys', PhD Thesis, University of Western Australia, 2005. |
| **Internet/Websites** | | |
| Website | [1] B. Dibble and B. Milech, *Elizabeth Jolley Research Collection*, [website], 2008, http://john.curtin.edu.au/jolley/index.html, (accessed 1 August 2010). | Dibble, B. and B. Milech, *Elizabeth Jolley Research Collection*,[website], 2008, http://john.curtin.edu.au/jolley/index.html, (accessed 1 August 2010). |
| Blog | [1] E. Woodbury, 'Manga Circulation in Japan', *Ooburoshiki*, [web blog], 1 February 2010, http://eugenewoodbury.blogspot.com/2010/02/manga-circulation-in-japan.html, (accessed 19 January 2010). | Woodbury, E., 'Manga Circulation in Japan', *Ooburoshiki*, [web blog], 1 February 2010, http://eugenewoodbury.blogspot.com/2010/02/manga-circulation-in-japan.html, (accessed 19 January 2010). |
| Digital Image | [1] R. Leighton, *Surf Sirens, Manly Beach, New South Wales, 1938-46* [online photograph], http://nla.gov.au/nla.pic-an14035743-4, (accessed 12 June 2010). | Leighton, R., *Surf Sirens, Manly Beach, New South Wales, 1938-46* [online photograph], http://nla.gov.au/nla.pic-an14035743-4, (accessed 12 June 2010). |
| **Multimedia/Audio-Visual** | | |
| Film or broadcast | [1] *The Red Badge of Courage*, dir. John Huston, USA, MGM, 1951, [videocassette]. | *The Red Badge of Courage*, dir. Huston, J., USA, MGM, 1951, [videocassette]. |
| Web Video | [1] *An Occasionally Accurate History of Australia: Part I*, [online video], 2006, http://www.youtube.com/watch?v=IJjNsCVHc34, (accessed 6 October 2010). | *An Occasionally Accurate History of Australia: Part I*, [online video], 2006, http://www.youtube.com/watch?v=IJjNsCVHc34, (accessed 6 October 2010). |

| | | |
|---|---|---|
| Podcast | [1] 'Fungi and Mould', *The Health Report*, [podcast], ABC Radio National,1999, http://www.abc.net.au/m/healthreport/stories/1999/48140.htm, (accessed 10 March 2003). | 'Fungi and Mould', *The Health Report*, [podcast], ABC Radio National, 1999, http://www.abc.net.au/m/healthreport/stories/1999/48140.htm, (accessed 10 March 2003). |
| **Oral Histories** | | |
| Interview | [1] John Edgar Maloney, interviewed by John Ferrell, 2004, John Curtin Prime Ministerial Library, Perth, JCMPL00897/3. | Maloney, J.E., interviewed by John Ferrell, 2004, John Curtin Prime Ministerial Library, Perth, JCMPL00897/3. |
| **Conference Proceedings** | | |
| Conference Proceeding | [1] G. Kozicz, 'Architecture of the Empty Shells of Nyar ma', *Discoveries in Western Tibet and the Western Himalayas: Essays on History, Literature, Archaeology and Art: PIATS 2003, Tibetan Studies, Proceedings of the Tenth Seminar of the International Association for Tibetan Studies.* Oxford, Oxford University Press, 2006, pp. 41-42. | Kozicz, G., 'Architecture of the Empty Shells of Nyar ma', *Discoveries in Western Tibet and the Western Himalayas: Essays on History, Literature, Archaeology and Art: PIATS 2003, Tibetan Studies, Proceedings of the Tenth Seminar of the International Association for Tibetan Studies.* Oxford, Oxford University Press, 2006, pp. 41-54. |
| **Citing Information Someone Else has Cited** | | |
| Citing information someone else has cited [citing "secondary" sources] | [1] A. Smith, *Italian architecture*, Penguin, Melbourne, 2000, cited in D. Brown, *Renaissance Italy*, London, Faber and Faber, 2002, p. 45. | In the reference list provide the details of the author who has done the citing: Brown, D., *Renaissance Italy*, London, Faber and Faber, 2002, p. 45. |

## ៤.៥. ផ្នែកឧបសម្ព័ន្ធ

គឺជាផ្នែកដែលភ្ជាប់ទៅនឹងនិក្ខេបបទនូវព័ត៌មានបន្ថែមផ្សេងៗ ដែលអាចនឹងមានប្រយោជន៍ក្នុងការវិនិច្ឆ័យឱ្យតម្លៃនិក្ខេបបទ ឬក្នុងការធ្វើការសិក្សានោះឡើងវិញ។ វាមិនមែនជាផ្នែកសំខាន់របស់និក្ខេបបទអត់មិនបាននោះទេ។ គេអាចដាក់ឈ្មោះជាឧបសម្ព័ន្ធ ក ឧបសម្ព័ន្ធ ខ ឧបសម្ព័ន្ធ គ ។ល។ ធម្មតាឧបសម្ព័ន្ធជាព័ត៌មាន ដូចជា៖ កម្រងសំណួរ ទម្រង់កំណត់ត្រាការសង្កេត ឬសម្ភាសន៍ ផែនទី រូបថត គំនូរ លិខិតផ្សេងៗ។ល។

## ៤.៦. ការកំណត់ទំព័រនិក្ខេបបទ

- និក្ខេបបទវិទ្យាសាស្ត្រសង្គមមានទំព័រសរុប ចាប់ពី១៥០ ដល់ ៣០០ទំព័រ។
- និក្ខេបបទវិទ្យាសាស្ត្រពិត មានទំព័រសរុប ចាប់ពី១០០ ដល់ ១៥០ទំព័រ។
- គម្រោងស្រាវជ្រាវពិស្តារមានទំព័រសរុប ចាប់ពី៥០ ដល់ ១០០ទំព័រ។
- គម្រោងស្រាវជ្រាវបឋមមានទំព័រសរុប ចាប់ពី១៥ ដល់ ៣០ទំព័រ។

❖ **ចំណាំ៖ គុណភាពនិក្ខេបបទ** សំដៅដល់និក្ខេបបទដែលត្រូវអនុវត្តដោយបេក្ខជនបណ្ឌិតផ្ទាល់ និងបំពេញតាមតម្រូវការនៃគោលបំណង និងលក្ខខណ្ឌដែលបានកំណត់។ ខ្លឹមសារនិក្ខេបបទបណ្ឌិតត្រូវមានបរិមាណ ពី១០០ទៅ៣០០ទំព័រ A4 ដែលនៅក្នុងនោះយ៉ាងតិច ៥០% (ហាសិបភាគរយ) គឺជាការបង្ហាញអំពីលទ្ធផលស្រាវជ្រាវ ការវិភាគ និងការបកស្រាយផ្ទាល់របស់បេក្ខជន។

# ជំពូកទី៥
# នីតិវិធី យន្តការការពារនិក្ខេបបទ
# និងការប្រគល់សញ្ញាបត្រថ្នាក់បណ្ឌិត

## ៥.១. ការការពារគម្រោងស្រាវជ្រាវពិស្តារ

នៅពេលដែលគម្រោងស្រាវជ្រាវបានសរសេរចប់ភ្លាម យើងត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការការពារគម្រោងស្រាវជ្រាវ។ គោលបំណងនៃការការពារគម្រោងស្រាវជ្រាវនេះ គឺផ្តល់ឱ្យបេក្ខជនបណ្ឌិតនូវការកែលម្អអំពីផ្នែកដែលអាចទទួលយកបានទាំងអស់របស់និក្ខេបបទ ដើម្បីក្លាយជាផែនទីសកម្មភាពស្រាវជ្រាវនិក្ខេបបទមួយដ៏ពេញលេញ និងប្រកបដោយក្តីសង្ឃឹមសម្រាប់ការចាប់ផ្តើមដំណើរការនៃការស្រាវជ្រាវជាក់លាក់។

មុនការការពារគម្រោងស្រាវជ្រាវអាចកំណត់ពេលបាន គណៈកម្មការសាស្ត្រាចារ្យណែនាំ ក្រុមទទួលបណ្តុះបណ្តាលថ្នាក់បណ្ឌិត និងសមាជិក ត្រូវអនុម័ត លើពាក្យស្នើសុំការពារគម្រោងស្រាវជ្រាវ និងយល់ព្រមថា បេក្ខជនបណ្ឌិតបានសរសេរគម្រោងស្រាវជ្រាវដែលប្រកបដោយគុណភាព អាចទទួលយកបាន។ ការកំណត់កាលបរិច្ឆេទ និងទីកន្លែង សម្រាប់ការពារគម្រោងនេះ ត្រូវធ្វើឡើងដោយសាលាក្រោយឧត្តម។ សកម្មភាពខាងក្រោមជាធម្មតា ត្រូវធ្វើឡើងអំឡុងពេលការពារគម្រោងស្រាវជ្រាវពិស្តារ៖

-បេក្ខជនបណ្ឌិតទាំងអស់ ត្រូវបានស្នើឱ្យធ្វើបទបង្ហាញសង្ខេបជាគោលក្នុងរយៈពេលពី២០-៣០នាទី អំពីខ្លឹមសារនៃគម្រោងស្រាវជ្រាវពិស្តាររបស់ខ្លួនឱ្យបានច្បាស់លាស់ និងងាយយល់បាន។

-ប្រធានគណៈកម្មការការពារនិក្ខេបបទ ត្រូវដើរតួជាអ្នកសម្របសម្រួល និងដឹកនាំការប្រជុំការពារនោះ។

-ក្រោយពីការធ្វើបទបង្ហាញរបស់បេក្ខជនបណ្ឌិត សមាជិក និង គណៈកម្មការវាយតម្លៃម្នាក់ៗ ត្រូវផ្តល់យោបល់ និងតាំងសំណួរឱ្យបំភ្លឺ ដើម្បីធ្វើ

ឱ្យប្រសើរឡើងដល់គម្រោងពិស្តារនោះ សម្រាប់ការអនុម័តឱ្យបេក្ខជនចាប់ផ្ដើមការស្រាវជ្រាវពិតប្រាកដ។

-បន្ទាប់មក បេក្ខជនបណ្ឌិត ត្រូវខិតខំទទួលយករាល់ការរិះគន់ ដើម្បីយកមកពិភាក្សាដោះស្រាយ ជាមួយគណៈកម្មការណែនាំនិក្ខេបបទនៅពេលការពារគម្រោងស្រាវជ្រាវ។ គណៈកម្មការការពារ ត្រូវហៅបេក្ខជនបណ្ឌិតប្រជុំដើម្បីបំពេញទម្រង់ការវាយតម្លៃលើការការពារគម្រោងស្រាវជ្រាវ។ នៅលើទម្រង់នេះ គណៈកម្មការត្រូវណែនាំដល់បេក្ខជនបណ្ឌិតពីការផ្លាស់ប្ដូរការពង្រីក ឬការលុបផ្នែកខ្លះនៃគម្រោងស្រាវជ្រាវ និងផ្ដល់ឱ្យបេក្ខជនបណ្ឌិតនូវសេចក្ដីលម្អិតនៃព័ត៌មានដែលបានស្នើ ឬការផ្លាស់ប្ដូរសំណើ។ បេក្ខជនបណ្ឌិត ត្រូវបានជម្រាបជូនអំពីការសម្រេចចិត្តរបស់គណៈកម្មការការពារក្រោយការវាយតម្លៃត្រូវបានបំពេញ។

### ៥.១.១. លក្ខខណ្ឌ និងការបំពេញសំណុំឯកសារ

ដើម្បីអនុញ្ញាតឱ្យការពារគម្រោងស្រាវជ្រាវពិស្តារ បេក្ខជនបណ្ឌិតត្រូវអនុវត្តតាមលក្ខខណ្ឌ និងបំពេញសំណុំឯកសារ ដូចខាងក្រោម៖

១-ពាក្យស្នើសុំការពារគម្រោងស្រាវជ្រាវ ចំនួន ០១ច្បាប់។

២-ប្រវត្តិរូបសង្ខេបមានបិទរូបថត( ៤x៦ ) ចំនួន ០១ច្បាប់។

៣-សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ថតចម្លង ដោយមានបញ្ជាក់ភាពត្រឹមត្រូវ ចំនួន ០២ច្បាប់។

៤-បញ្ជីឈ្មោះអនុញ្ញាតឱ្យចូលសិក្សាថ្នាក់បណ្ឌិត ចំនួន ០១ច្បាប់

៥-លិខិតបញ្ជាក់ជាបេក្ខជនបណ្ឌិត ចំនួន ០១ច្បាប់។

៦-ព្រឹត្តបត្រពិន្ទុសិក្សាមុខវិជ្ជាថ្នាក់បណ្ឌិត (ត្រូវជាប់គ្រប់មុខវិជ្ជា) ចំនួន ០១ច្បាប់។

៧-គម្រោងស្រាវជ្រាវពិស្តារ ដែលមានចុះហត្ថលេខាឯកភាពពី សាស្ត្រាចារ្យណែនាំទាំងពីរ ចំនួន ០៣ច្បាប់។

៨-លិខិតបញ្ជាក់ពីអង្គភាពសាមី ចំនួន ០១ច្បាប់។

**៥.១.២. យន្តការនៃដំណើរការការពារ**

ក្រោយពីបេក្ខជនបណ្ឌិត បានបំពេញតាមលក្ខខណ្ឌខាងលើរួចមក យ៉ាងយូរមួយសប្តាហ៍ សាលាក្រោយឧត្តម នឹងរៀបចំសមាសភាពគណៈកម្មការវាយតម្លៃជូនសាកលវិទ្យាធិការ ដើម្បីពិនិត្យ និងសម្រេច។

សមាសភាពគណៈកម្មការវាយតម្លៃមានចំនួន ៧រូប។ បេក្ខជនបណ្ឌិតត្រូវការពារគម្រោងស្រាវជ្រាវពិស្តារជាផ្លូវការ និងជាសាធារណៈនៅចំពោះមុខគណៈកម្មការនេះ។

**៥.១.៣. ការប្រកាសលទ្ធផលការពារ**

ក្រោយពីការវាយតម្លៃត្រូវបានបញ្ចប់ដោយសមាជិក សមាជិកា គណៈកម្មការម្នាក់ៗរួចមក ប្រធានគណៈកម្មការការពារត្រូវប្រកាសនូវលទ្ធផលឱ្យដល់បេក្ខជនបណ្ឌិតបានជ្រាបដូចខាងក្រោម៖

-អនុញ្ញាតឱ្យស្រាវជ្រាវបន្ត។

-អនុញ្ញាតឱ្យស្រាវជ្រាវបន្ត ដោយកែលម្អចំណុចមួយចំនួនតាមការណែនាំរបស់គណៈកម្មការ។

-មិនអនុញ្ញាតឱ្យស្រាវជ្រាវបន្ត ដោយត្រូវឱ្យរៀបចំជាថ្មីឡើងវិញ។ ក្នុងករណីនេះនិស្សិត និងសាស្ត្រាចារ្យណែនាំ ពិភាក្សាពីលទ្ធភាពកែលម្អតាមអនុសាសន៍របស់គណៈកម្មការវាយតម្លៃ រួចដាក់ពាក្យស្នើសុំការពារសាជាថ្មី។

**៥.២. ការការពារនិក្ខេបបទសាកល្បង**

និស្សិតត្រូវការពារនិក្ខេបបទសាកល្បង និងជាសាធារណៈ នៅចំពោះមុខគណៈកម្មការ ដែលរៀបចំដោយសាលាក្រោយឧត្តម តាមសំណើសុំរបស់សាមីខ្លួន និងមានការយល់ព្រមពីក្រុមសាស្ត្រាចារ្យណែនាំ។

**៥.២.១. លក្ខខណ្ឌ និងការបំពេញសំណុំឯកសារ**

ដើម្បីអនុញ្ញាតឱ្យការពារសាកល្បងនិក្ខេបបទបណ្ឌិត បេក្ខជនបណ្ឌិតត្រូវអនុវត្តតាមលក្ខខណ្ឌ និងបំពេញសំណុំឯកសារដូចខាងក្រោម៖

១-ពាក្យស្នើសុំការពារនិក្ខេបបទសាកល្បង ចំនួន ០១ច្បាប់។

២-សេចក្តីប្រកាសលទ្ធផលវាយតម្លៃបូកសរុបរបស់គណៈកម្មការវាយតម្លៃការការពារគម្រោងស្រាវជ្រាវពិស្តារដោយជោគជ័យ ចំនួន ០១ច្បាប់។

៣-របាយការណ៍ស្តីពីការកែលម្អតាមគណៈកម្មការវាយតម្លៃ ដោយមានការបញ្ជាក់ពីសាស្ត្រាចារ្យណែនាំ និងប្រធានគណៈកម្មការវាយតម្លៃ ចំនួន ០១ច្បាប់។

៤-និក្ខេបបទដែលត្រូវការពារសាកល្បង ដោយមានចុះហត្ថលេខាឯកភាពពីសាស្ត្រាចារ្យណែនាំទាំងពីរ ចំនួន ០៣ច្បាប់។

៥-សៀវភៅសង្ខេបនិក្ខេបបទ ចំនួន ០៣ច្បាប់។

៦-ស្លាយ (Slide) សម្រាប់ធ្វើបទបង្ហាញ ចំនួន ០៣ច្បាប់។

៧-អត្ថបទធ្វើសិក្ខាសាលាលើកទី១ ចំនួន ០១ច្បាប់។

៨-អត្ថបទផ្សព្វផ្សាយស្នាដៃក្នុងទស្សនាវដ្តីវិទ្យាសាស្ត្រលើកទី១ ចំនួន ០១ច្បាប់។

**៥.២.២. យន្តការនៃដំណើរការការពារ**

ក្រោយពីបេក្ខជនបណ្ឌិត បានបំពេញតាមលក្ខខណ្ឌខាងលើរួចមកយ៉ាងយូរមួយសប្តាហ៍ សាលាក្រោយឧត្តម នឹងរៀបចំសមាសភាពគណៈកម្មការវាយតម្លៃជូនសាកលវិទ្យាធិការ ដើម្បីពិនិត្យនិងសម្រេច។

សមាសភាពគណៈកម្មការវាយតម្លៃមានចំនួន ៧រូប។ បេក្ខជនបណ្ឌិតត្រូវការពារនិក្ខេបបទសាកល្បងជាផ្លូវការ និងជាសាធារណៈនៅចំពោះមុខគណៈកម្មការនេះ។

សាស្ត្រាចារ្យវាយតម្លៃ ត្រូវបញ្ជូនរបាយការណ៍វាយតម្លៃអំពីគុណភាពនិក្ខេបបទមកសាកលវិទ្យាល័យវិញ ក្នុងរយៈពេលមួយខែបន្ទាប់ពីបានទទួលនិក្ខេបបទ។ បេក្ខជន និងសាស្ត្រាចារ្យណែនាំត្រូវពិភាក្សាគ្នាអំពីលទ្ធភាពកែលម្អតាមរបាយការណ៍របស់សាស្ត្រាចារ្យវាយតម្លៃ។ ក្រោយពេលកែលម្អរួច

បេក្ខជនត្រូវផ្ញើនិក្ខេបបទថ្មីនេះចំនួនបីក្បាលមកសាកលវិទ្យាល័យ ដើម្បីពិនិត្យ និងចេញសេចក្តីសម្រេចៈ

- អនុញ្ញាត ឬមិនអនុញ្ញាតឱ្យការពារ។
- សមាសភាពគណៈកម្មការវាយតម្លៃដែលមានចំនួន ៧រូប (ករណីអនុញ្ញាត)។

### ៥.២.៣. ការប្រកាសលទ្ធផលការពារ

- អនុញ្ញាតឱ្យបន្តការស្រាវជ្រាវ ដោយមានអនុសាសន៍កែលម្អ។
- មិនអនុញ្ញាតឱ្យបន្តការស្រាវជ្រាវ ដោយមានអនុសាសន៍កែលម្អច្រើនពេក។ ក្នុងករណីនេះនិស្សិត និងសាស្ត្រាចារ្យណែនាំ ពិភាក្សាពីលទ្ធភាពកែលម្អ តាមអនុសាសន៍របស់គណៈកម្មការវាយតម្លៃ រួចដាក់ពាក្យស្នើសុំការពារសាជាថ្មីឡើងវិញ។

## ៥.៣. ការការពារនិក្ខេបបទបញ្ចប់

សាកលវិទ្យាល័យ នឹងត្រូវបញ្ជូនសំណុំលិខិតរបស់បេក្ខជនបណ្ឌិតទៅក្រសួងអប់រំ យុវជន និងកីឡា ដើម្បីស្នើសុំការពារនិក្ខេបបទបញ្ចប់។

និស្សិតត្រូវការពារនិក្ខេបបទបញ្ចប់ជាផ្លូវការ និងជាសាធារណៈ នៅចំពោះមុខគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទបញ្ចប់ ដែលស្នើឡើងដោយសាកលវិទ្យាល័យ និងមានការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឡា។

### ៥.៣.១. លក្ខខណ្ឌ និងការបំពេញសំណុំឯកសារ

ដើម្បីអនុញ្ញាតឱ្យការពារនិក្ខេបបទបញ្ចប់ថ្នាក់បណ្ឌិត បេក្ខជនបណ្ឌិតត្រូវអនុវត្តតាមលក្ខខណ្ឌនិងបំពេញសំណុំឯកសារដូចខាងក្រោមៈ

១-ពាក្យស្នើសុំការពារនិក្ខេបបទបញ្ចប់ ចំនួន ០១ច្បាប់។

២-សេចក្តីប្រកាសលទ្ធផលវាយតម្លៃបូកសរុបរបស់គណៈកម្មការវាយតម្លៃការការពារនិក្ខេបបទសាកល្បងដោយជោគជ័យ ចំនួន ០១ច្បាប់។

៣-របាយការណ៍ស្តីពីការកែលម្អតាមគណៈកម្មការវាយតម្លៃ ដោយមានការបញ្ជាក់ពីសាស្ត្រាចារ្យណែនាំ និងប្រធានគណៈកម្មការវាយតម្លៃ ចំនួន ០១ច្បាប់។

៤-និក្ខេបបទដែលត្រូវការពារបញ្ចប់ ដោយមានចុះហត្ថលេខាឯកភាពពីសាស្ត្រាចារ្យណែនាំទាំងពីរ ចំនួន ០៣ច្បាប់។

៥-សៀវភៅសង្ខេបនិក្ខេបបទ ចំនួន ០៣ច្បាប់។

៦-ស្លាយ (Slide) សម្រាប់ធ្វើបទបង្ហាញ ចំនួន ០៣ច្បាប់។

៧-អត្ថបទធ្វើសិក្ខាសាលាលើកទី២ ចំនួន ០១ច្បាប់។

៨-អត្ថបទផ្សព្វផ្សាយស្នាដៃក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រ លើកទី២ ចំនួន ០១ច្បាប់។

**៥.៣.២. យន្តការនៃដំណើរការការពារ**

បន្ទាប់ពីបេក្ខជនបណ្ឌិត បានការពារនិក្ខេបបទសាកល្បងដោយជោគជ័យ និងបានកែលម្អតាមគណៈកម្មការវាយតម្លៃរួចមក បេក្ខជនបណ្ឌិតអាចដាក់ពាក្យស្នើសុំការពារនិក្ខេបបទបញ្ចប់បាន។

ក្រោយពីបានពិនិត្យលក្ខខណ្ឌ និងនីតិវិធីរួចមក សាកលវិទ្យាល័យនឹងរៀបចំសមាសភាពគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទបញ្ចប់ ដោយមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

**៥.៣.៣. ការប្រកាសលទ្ធផលការពារ**

មានមួយក្នុងចំណោម ៤ កម្រិត ដូចខាងក្រោម៖

**កម្រិតទី១៖** និក្ខេបបទមានតម្លៃជានិក្ខេបបទកម្រិតបណ្ឌិត ដោយគ្មានការកែលម្អ។

**កម្រិតទី២៖** និក្ខេបបទមានតម្លៃជានិក្ខេបបទកម្រិតបណ្ឌិត ដោយមានការកែលម្អ។ ករណីនេះបេក្ខជន និងសាស្ត្រាចារ្យ ណែនាំត្រូវពិភាក្សាគ្នាអំពីលទ្ធភាពកែលម្អ តាមអនុសាសន៍របស់គណៈកម្មការវាយតម្លៃ។ បន្ទាប់មក បេក្ខជនបណ្ឌិត

ត្រូវយកលទ្ធផលកែលម្អ ដោយមានចុះហត្ថលេខាឯក-ភាព ពីសាស្ត្រាចារ្យណែនាំទាំងពីរ ដាក់ជូនគណៈកម្មការវាយតម្លៃ ដើម្បីពិនិត្យ និងសម្រេច។

**កម្រិតទី៣៖** និក្ខេបបទពុំទាន់មានតម្លៃជានិក្ខេបបទកម្រិតបណ្ឌិត ប៉ុន្តែបេក្ខជនបណ្ឌិត ត្រូវបានផ្តល់ឱកាសឱ្យដាក់និក្ខេបបទ ដើម្បីសុំពិនិត្យ និងវាយតម្លៃសាជាថ្មីម្តងទៀត បន្ទាប់ពីបានកែសម្រួលនិក្ខេបបទឡើងវិញរួចរាល់ យ៉ាងយូរបំផុតត្រឹម ២៤ខែ គិតចាប់ពីថ្ងៃដែលបានការពារលើកទីមួយ។

**កម្រិតទី៤៖** និក្ខេបបទមិនត្រូវបានអនុញ្ញាតឱ្យការពារជាលើកទី៣។

## ៥.៤. លក្ខខណ្ឌសម្រាប់អនុញ្ញាតឱ្យការពារនិក្ខេបបទបញ្ចប់

និស្សិតត្រូវបំពេញគ្រប់លក្ខខណ្ឌ ដើម្បីទទួលបានការអនុញ្ញាតឱ្យការពារនិក្ខេបបទបញ្ចប់ដូចខាងក្រោម៖

- និស្សិតត្រូវបញ្ចប់ដោយជោគជ័យគ្រប់មុខវិជ្ជាសិក្សា នៅដំណាក់កាលទី១ ហើយប្រគល់និក្ខេបបទសម្រាប់ការវាយតម្លៃ។
- និស្សិតត្រូវផ្តល់កាលបរិច្ឆេទនៃការបញ្ចប់ដោយជោគជ័យ និងលទ្ធផលវង្វាយតម្លៃនីមួយៗសម្រាប់គ្រប់មុខវិជ្ជាសិក្សា និងការប្រឡងទូទៅ ការចូលរួមសិក្ខាសាលា និងធ្វើសិក្ខាសាលាឱ្យគ្រប់តាមចំនួនកំណត់ និងការចុះផ្សាយអត្ថបទស្រាវជ្រាវកម្រិតជាតិ ឬកម្រិតអន្តរជាតិ យ៉ាងហោចណាស់ឱ្យបានរយៈពេលបួន (៤)ខែ មុនការឡើងការពារនិក្ខេបបទបញ្ចប់។
- និស្សិតត្រូវបានគាំទ្រ ដោយគណៈកម្មការពិនិត្យនិងវាយតម្លៃឯករាជ្យដោយសម្លេងភាគច្រើន។

## ៥.៥. ការការពារនិក្ខេបបទឡើងវិញ

បេក្ខជនបណ្ឌិត ដែលពុំទទួលបានជោគជ័យក្នុងការការពារនិក្ខេបបទបញ្ចប់ត្រូវបានអនុញ្ញាតឱ្យការពារនិក្ខេបបទឡើងវិញ តាមលក្ខខណ្ឌដូចខាងក្រោម៖

- បេក្ខជនបណ្ឌិតត្រូវកែសម្រួលនិក្ខេបបទឡើងវិញ ហើយដាក់ស្នើសុំការពារជាលើកទីពីរយ៉ាងយូរបំផុតត្រឹម ២៤ខែ គិតចាប់ពីថ្ងៃដែលបានការពារលើកទីមួយ។

- សមាសភាពគណៈកម្មការវាយតម្លៃនិក្ខេបបទឡើងវិញ ត្រូវដូចគ្នាទៅនឹងសមាសភាពគណៈកម្មការវាយតម្លៃនិក្ខេបបទឡើងវិញ ត្រូវដូចគ្នាទៅនឹងសមាសភាពគណៈកម្មការវាយតម្លៃបញ្ចប់ដែរ។ ករណីមានសមាជិកសមាជិកាគណៈកម្មការណាមួយ អវត្តមានសាកលវិទ្យាល័យនឹងស្នើឈ្មោះសុំមកក្រសួងអប់រំ យុវជន និងកីឡា ដើម្បីបំពេញជំនួស។

- មិនអនុញ្ញាតឱ្យការពារនិក្ខេបបទជាលើកទីបីឡើយ។

## ៥.៦. របៀបវារៈនៃដំណើរការការពារ

១-ប្រកាសកម្មវិធី និងជីវប្រវត្តិសង្ខេបរបស់បេក្ខជនបណ្ឌិតដោយតំណាងសាលាក្រោយឧត្តម។

២-ប្រធានគណៈកម្មការវាយតម្លៃដឹកនាំ និងសម្របសម្រួលកម្មវិធីការពារ។

៣-បទបង្ហាញខ្លឹមសារនិក្ខេបបទសង្ខេប ដោយបេក្ខជនបណ្ឌិតរយៈ-ពេល ២០ ទៅ ៣០នាទី។

៤-ការផ្តល់យោបល់កែលម្អ និង/ឬផ្តល់សំណួរ ដោយគណៈកម្មការវាយតម្លៃ។

៥-ការបកស្រាយនូវសំណួររបស់គណៈកម្មការវាយតម្លៃ ដោយបេក្ខជនបណ្ឌិត។

៦-ការសម្រាករយៈពេល១៥នាទី ដើម្បីគណៈកម្មការវាយតម្លៃបូកសរុប និងធ្វើការវាយតម្លៃ។

៧-ការប្រកាសលទ្ធផលសម្រេច ដោយប្រធានគណៈកម្មការវាយតម្លៃ។

## ៥.៧. លិខិតូបករណ៍

ដើម្បីសម្រួលដល់នីតិវិធីការងារ និងដំណើរនៃការការពារនិក្ខេបបទឱ្យបានរលូនអង្គភាពគ្រប់គ្រងក្រោយថ្នាក់បរិញ្ញាបត្រ បានរៀបចំគំរូលិខិតូបករណ៍ដូចមានក្នុងឧបសម្ព័ន្ធនៃសេចក្ដីណែនាំនេះ សម្រាប់ការការពារគម្រោងស្រាវជ្រាវពិស្ដារ ការពារនិក្ខេបបទសាកល្បង និងការពារនិក្ខេបបទបញ្ចប់ដូចខាងក្រោម៖

-ពាក្យស្នើសុំការពារ។

-របាយការណ៍ស្ដីពីការពិនិត្យវាយតម្លៃរបស់គណៈកម្មការវាយតម្លៃ។

-កំណត់ត្រាវាយតម្លៃរបស់គណៈកម្មការវាយតម្លៃ។

-សេចក្ដីប្រកាសលទ្ធផលវាយតម្លៃបូកសរុបរបស់គណៈកម្មការវាយតម្លៃ។

-បញ្ជីវត្តមានសមាសភាពគណៈកម្មការវាយតម្លៃ។

-របាយការណ៍ស្ដីពីការកែលម្អតាមគណៈកម្មការវាយតម្លៃ។

-លិខិតរដ្ឋបាលសិក្សា ដែលពាក់ព័ន្ធដទៃទៀត។

## ៥.៨. ការប្រគល់សញ្ញាបត្រ

### ៥.៨.១. វិញ្ញាបនបត្របណ្ដោះអាសន្ន

រយៈពេលមួយខែ ក្រោយពីគណៈកម្មការវាយតម្លៃនិក្ខេបបទបញ្ចប់ថ្នាក់ជាតិ ប្រកាសយល់ព្រមឱ្យជាប់ជាស្ថាពររួចមក សាកលវិទ្យាល័យអាចចេញសញ្ញាបត្របណ្ដោះអាសន្នជូនបានតាមការស្នើសុំពីសាមីជន។

### ៥.៨.២. ការតម្កល់និក្ខេបបទ និងសញ្ញាបត្របណ្ឌិត

ក្រោយពីបានប្រកាសឱ្យជាប់កម្រិតបណ្ឌិតជាស្ថាពររួច យ៉ាងយូររយៈពេលប្រាំមួយខែ សាមីបណ្ឌិត ត្រូវយកនិក្ខេបបទចំនួន ០៥ច្បាប់ (Hard Copy) ដែលបានកែសម្រួល និងសម្រិតសម្រាំងរួច ដោយមានហត្ថលេខា

ឯកភាពពីសាស្ត្រាចារ្យណែនាំ និងគណៈកម្មការវាយតម្លៃមកតម្កល់ និងផ្នែកទន់ ( Soft Copy ) មកតម្កល់ទុកនៅសាកលវិទ្យាល័យ ដើម្បីជាលក្ខខណ្ឌក្នុងការប្រគល់សញ្ញាបត្របណ្ឌិត។